Help Me Grow Maine

2-1-1 Maine

# ដំណោះស្រាយសម្រាប់ជួយឲ្យកុមារលូតលាស់

Help Me Grow គឺជាចំណុចកណ្តាលសម្រាប់ជួយ ឲ្យអ្នកជំងឺទទួលបានសេវា ដែលបានរៀបចំឡើងដើម្បីផ្សារភ្ជាប់ គ្រួសារជាមួយនឹងព័ត៌មាន និង សេវានានាអំពីការលូតលាស់របស់កុមារ  និងធនធានសហគមន៍ ។

ក្នុងភាពជាដៃគូជាមួយនឹង 2-1-1 Maine អ្នកមើលថែ និងអ្នកផ្តល់សេវាមើលថែកុមារ អាច ទាក់ទង Help Me Grow ដើម្បីស្នើសុំ ការជ្រាមជ្រែងបន្ថែម ។Help Me Grow នឹងស្តាប់, ភ្ជាប់គ្រួសារអ្នកជំងឺជាមួយនឹង សេវា ព្រមទាំងជួយតាមដានជាមួយនឹង អ្នកមើលថែកុមារ និងធនធាន សម្រាប់ចាត់បញ្ជូនអ្នកជំងឺ ។

## តើវាមានដំណើរការបែបណា៖

### ភាពមានសិទ្ធិទទួលសេវា

យើងខ្ញុំមានវត្តមានចាំជួយកុមារទាំងអស់នៅក្នុងរដ្ឋមេន ដោយមិនគិតថ្លៃ ចាប់ពីពេលកើតដល់អាយុប្រាំបីឆ្នាំ ព្រមទាំងគ្រួសារ/អ្នកមើលថែរបស់កុមារទាំងនោះផងដែរ ។ ឪពុកម្តាយក្មេងក៏អាចហៅទូរស័ព្ទស្នើសុំជំនួយបានផងដែរក្នុងពេលមានផ្ទៃពោះ ។

### ចំណុចសម្រាប់ទំនាក់ទំនងកណ្តាល

យើងខ្ញុំជួយអ្នកមើលថែកុមារ និងអ្នកផ្តល់សេវាថែទាំសុខភាពកុមារ ដោយការតភ្ជាប់កុមារជាមួយនឹងបណ្តាញនៃធនធានសហគមន៍ និងធនធានរបស់រដ្ឋដែលមានស្រាប់ ដែលអាចជួយពួកគេឲ្យរីកចម្រើន តាមរយៈ "ការផ្ទេរដ៏កក់ក្តៅ" ពីគ្រួសារកុមារ ទៅកាន់ធនធាន ។

### ធនធាន

យើងខ្ញុំជួយជ្រោមជ្រែងបណ្តាញអ្នកផ្តល់សេវាដែលភ្ជាប់គ្នាដែលអាចជួយផ្តល់សេវាដល់គ្រួសារកុមារប្រកបដោយប្រសិទ្ធិភាពនៅក្នុងរដ្ឋមេន ដែលមានតម្រូវការផ្សេងៗ ។

### ការពិនិត្យអំពីការលូតលាស់របស់កុមារ

យើងខ្ញុំលើកកម្ពស់ចំពោះការធ្វើការជាមួយនឹងគ្រួសារកុមារដើម្បីរកឲ្យឃើញនូវគោលសំខាន់អំពីការលូតលាស់របស់កុមារ និងចេះប្រើកម្រងបញ្ជីសំណួរអាយុ និងដំណាក់កាល (Ages & Stages Questionnaires® (ASQ)) សម្រាប់វាយតម្លៃអំពីការលូតលាស់របស់កុមារ ។ បើសិនជាកំណត់ឃើញនូវក្តីបារម្ភ នៅក្នុងដំណើរការនៃការពិនិត្យ គឺយើងខ្ញុំនឹងធ្វើការជាមួយគ្រួសារកុមារដើម្បីតភ្ជាប់ជាមួយនឹងអ្នកមានវិជ្ជាជីវៈផ្នែកការអន្តរាគមន៍ពេលកុមារនៅតូច សម្រាប់ធ្វើការ វាយតម្លៃបន្ថែម ។

## ពិចារណាអំពីការបញ្ជូនគ្រួសារអ្នកជំងឺ នៅពេល៖

- អ្នកមិនប្រាកដថា តើសេវាអ្វីដែលគ្រួសារកុមារអាចមានសិទ្ធិទទួល តែអ្នកគ្រាន់តែដឹងថាពួកគេត្រូវការការជ្រោមជ្រែង ។

- គ្រួសាររបស់កុមារ ត្រូវការជំនួយបន្ថែមក្នុងការឈានបន្តទៅក្នុង ជំហានបន្ទាប់ក្នុងការទទួលបានធនធាន (ដូចជាធនធាន CDS, WIC, ។ល។) ។

-ការពិនិត្យត្រូវតែធ្វើឲ្យចប់ចុងចប់ដើម ឬគ្រួសារដែល  ត្រូវការជំនួយ ក្នុងការបំពេញកម្រងសំណួរ ASQ® តាមអនឡាញ ។



ស្កេនកូដ QR ខាងស្តាំ ដើម្បីទទួលបានព័ត៌មានបន្ថែម

នាយកដ្ឋានសេវាសុខភាព និងពលរដ្ឋ (DHHS) មិនមានការរើសអើងទេ ។